# ផែនការរៀបចំមេរៀនសំរាប់គ្រូ

សូមពិនិត្យមើលទំព័រ១ និង ២ នៃ "របៀបក្នុងការប្រើប្រាស់សៀវភៅណែនាំរបស់គ្រូនេះ"
សំរាប់ព័ត៌មានអំពីការប្រើនៃផែនការ នៃការរៀបចំមេរៀនទាំងនេះ

# គំនិតទូទៅនៃវគ្គសិក្សានេះ

**១.** មួយថ្ងៃ ឬ ពីរថ្ងៃមុនពេលបើកថ្នាក់ដំបូង អ្នកត្រូវតែណែនាំមេរៀននេះទៅដល់សិស្សទាំងអស់ ហើយផ្តល់កិច្ចការត្រូវធ្វើ ដំបូងដល់ពួកគេ ។ ប្រសិនបើអាចធ្វើបានត្រូវផ្តល់សៀវភៅណែនាំការសិក្សាមួយថ្ងៃ ឬ ពីរថ្ងៃមុនពេលចាប់ផ្តើមការបង្រៀនវគ្គសិក្សានេះ ។

**២.** នៅទំព័របន្ទាប់ពីនេះ( ទំព័រ ២) មានបញ្ជីកិច្ចការត្រូវធ្វើមួយសន្លឹក រួមជាមួយនឹងកាលបរិច្ឆេទ នៅពេលណាកិច្ចការត្រូវបានបំពេញរួច ។ ចូរអោយពួកគេបំពេញកាលបរិច្ឆេទអោយបានត្រឹមត្រូវដោយប្រើក្រដាស ស នៅទំព័រនៃបញ្ជីកិច្ចការត្រូវធ្វើនៅខាងក្រោយនៃសៀវភៅណែនាំសំរាប់ការសិក្សានេះ ។

**៣.** ជំរាបអោយសិស្សដឹងថា ពួកគេត្រូវបញ្ចប់ គំរោង ទី ១ និង ទី ២នៅពេលដែលពួកគេវិលមកចូលរៀនថ្នាក់ដំបូង ។ អ្នកអាចពន្យល់ដោយសង្ខេបនៃគំរោង ទី ២ ដល់សិស្ស។ គំរោងនេះសូមអោយពួកគេរកអោយឃើញនូវតំរូវការនិងចំណង់ដែលអារក្សសាតាំងកំពុងតែព្យាយាមអោយពួកគេធ្វើនៅក្នុងជីវិតរបស់ពួកគេនៅពេលដែលពួកគេជួបការល្បួង ។( សូមមើល សំនួរ ទី ៤ និង ៥ នៅក្នុងគំរោង ទី ២ ) យើងនឹងពិភាក្សានូវបញ្ហានេះនៅក្នុងថ្នាក់ដំបូង ។

សូមប្រាប់ពួកគេប្រសិនបើពួកគេមិនយល់ អ្វីត្រូវសរសេរ សូមទុកវាចោល ។ ពួកគេអាចបញ្ចប់នៅផ្នែកនោះនៃគំរោ ងទី ២ នៅក្នុងកំឡុងពេលរៀន ឬក៏ បន្ទាប់ពីថ្នាក់រៀនដំបូង ។ ប៉ុន្តែពួកគេត្រូវបំពេញអោយហើយនៅសំនួរដំបូង ៣ នៅគ្រប់ទាំង ឧទាហរណ៏ទាំង ៣ ក្នុងគំរោង ទី ២ មុននឹងថ្នាក់ដំបូងចាប់ផ្តើម ។

**៤.** សៀវភៅណែនាំរបស់សិស្សអាចត្រូវផ្តល់ដល់សិស្សនៅពេលវេលាដូចគ្នាដែលអ្នកណែនាំអោយស្គាល់វគ្គសិក្សាប្រគល់ជូនផងដែរនូវ សៀវភៅណែនាំការសិក្សា ។ ឬក៏ អ្នកអាចរងចាំ ហើយប្រគលសៀវភៅណែនាំរបស់សិស្សនៅថ្នាក់ដំបូងរបស់អ្នក ។ ប្រសិនបើអ្នកជ្រើសរើសប្រគល់វាមុនចាប់ផ្តើមរៀនថ្នាក់ដំបូង សូមអោយសិស្សរបស់អ្នកអានទំព័រ ទី ១ ដល់ ទី ១០ ដើម្បីរៀបចំសំរាប់ថ្នាក់រៀនដំបូង ។

# បញ្ជីកិច្ចការគ្រូធ្វើនៅក្នុងថ្នាក់

**ចំណងជើងមេរៀន :** ការល្បួង

| **សំនួរខ្លីៗ** | **ខចងចាំ** | **កាលបរិច្ឆេទ** |
|---|---|---|
| ១ | ១ កូរិនថូស ១០:១៣ | ថ្ងៃ ទី ២ |
| ២ | យ៉ាកុប ៤:៧-៨ | ថ្ងៃ ទី ៣ |
| ៣ | គំរូសំរាប់យកជ័យជំនះលើការល្បួង | ថ្ងៃ ទី ៤ |

| **គំរោង** | **ថ្ងៃខែផុតកំណត់** |
|---|---|
| ១ | ថ្ងៃ ទី ១ |
| ២ | ថ្ងៃ ទី ១ |
| ៣ | ថ្ងៃ ទី ២ |
| ៤ | ថ្ងៃ ទី ២ |
| ៥ | ថ្ងៃ ទី ៣ |
| ៦ | ថ្ងៃ ទី ៣ និង ទី ៤ |
| ៧ | ថ្ងៃ ទី ៣ និង ទី ៤ |
| ៨ | ថ្ងៃ ទី ៤ |

**ការប្រលង :** កាលបរិច្ឆេទ ថ្ងៃ ទី ៥

# មេរៀន ទី១

# ការបង្កើតនូវការយល់ដឹងនៃសេចក្តីត្រូវការរបស់ខ្ញុំ

**១. សេចក្តីពិតសំខាន់ៗនៅក្នុងព្រះគម្ពីរ**

ខ្ញុំចាំបាច់ត្រូវតែរកអោយឃើញតំរូវការនៅក្នុងជីវិតរបស់ខ្ញុំដែលសាតាំងកំពុងតែព្យាយាមល្បួងខ្ញុំអោយធ្លាក់ទៅក្នុងផ្លូវរបស់វា ។

**២. ខ គម្ពីរសំខាន់ : ភីលីព ៤:១៩**

ព្រះរបស់ខ្ញុំនឹងបំពេញសេចក្តីត្រូវការគ្រប់យ៉ាងរបស់បងប្អូន ស្របតាមសិរីរុងរឿងដ៏ប្រសើរបំផុតរបស់ព្រះអង្គ ដោយរួមក្នុងអង្គព្រះគ្រិស្តយេស៊ូ ។

**៣. សំភារៈសិក្សាយោងរបស់សិស្ស**

នៅទំព័រ ទី ១-១០ នៅក្នុងការសៀវភៅណែនាំរបស់សិស្សស៊ីគ្នាជាមួយមេរៀននេះ ។ គំរោង ទី ១ និង ២ នៅក្នុងសៀវភៅណែនាំការសិក្សានឹងត្រូវបានប្រើក្នុងមេរៀននេះ ។

**៤. មេរៀនស្វាគមន៍គ្នាមុនពេលសិក្សា ( ៥ នាទី )**

ដើម្បីណែនាំអោយស្គាល់មេរៀននេះ ត្រូវមានសិស្សជាច្រើនឆ្លើយតបទៅនឹងសំនួរនេះ ។ ឧបមាថា អ្នកជាអាដាំ និង អេវ៉ានៅក្នុងសួនច្បារអេដែនមួយនាទី ។ អ្នកដឹងថា ព្រះជាម្ចាស់បានដាក់ដើមឈើមួយ ដើម ហើយព្រះអង្គមានព្រះបន្ទូលថា អ្នកមិនអាចញ៉ាំផ្លែឈើនោះទេ ។ យើងទាំងអស់គ្នាដឹងថា អាដាំ និង អេវ៉ា បានបរិភោគ ផ្លែឈើនោះ នឹងត្រូវបានបណ្តេញចេញពីសួនច្បារ ។ ប្រសិនបើអ្នកជាអាដាំ និង អេវ៉ា តើអ្នកគួរតែធ្វើអ្វីចំពោះដើមឈើមួយដើមនេះ?

**៥. ការល្បួងនៅក្នុងជីវិតរបស់គ្រិស្តបរិស័ទ (៥ នាទី )**

ចំណាយពីរបីនាទីដើម្បីពន្យល់ តើការល្បួងដាក់អ្វីនៅក្នុងជីវិតរប់សគ្រិស្តបរិស័ទ ។ ពួកគេចាំបាច់ត្រូវយល់ដឹង ថា ការល្បួងគឺជាផ្នែកមួយប៉ុណ្ណោះនៃជីវិតរបស់គ្រិស្តបរិស័ទ ។

ពួកគេមិនគួរមើលគ្រប់ទាំងស្ថានភាពទាំងអស់នៅក្នុងជីវិតជាឱកាសត្រូវបានគេល្បួងអោយធ្វើអំពើបាបនោះទេ ។ថ្ងៃខ្លះពួកគេប្រហែលជាប្រឈមមុខទៅនឹងការល្បួងជាច្រើន ប៉ុន្តែថ្ងៃដទៃទៀតពួកគ្មានមួយទាល់តែតែសោះ ។ ជាគ្រិស្ត បរិស័ទ ពេញវ័យជារៀងរាល់ថ្ងៃយើងត្រូវតែមានការត្រូវធ្វើច្រើនជាងការតយុតជាមួយការល្បួង ។ សូមមើល ទំព័រ ៤-៧នៅក្នុងការណែនាំរបស់សិស្សសំរាប់ពតិមានបន្ថែមនៅលើចំណុចនេះ ។

## ៦. តើការល្បួងគឺជាអ្វី? (៥-១០នាទី)

ចង្អុលបង្ហាញចំណុចសំខាន់ៗរវាងការល្បួងដែលនាំអោយមានការរីកចំរើន( ជាធម្មតាយើងហៅថា ការសាកល្បង) និង ការល្បួងដែលនាំអោយធ្វើអំពើបាប-ដែលវាតែងតែនាំអោយវិនាសប្រសិនបើគ្រីស្តបរិស័ទធ្វើតាមវា ។ សូមផ្តល់ ឧទាហរណ៍អោយបានច្រើនអំពីការល្បួងទាំងពីរនេះបន្ទាប់មកពន្យល់ថា នៅក្នុងកំឡុងពេលនៃមុខវិជ្ជានេះទាំងមូល យើងនឹង ពិភាក្សា ការល្បួងដែលនាំអោយធ្វើអំពើបាប មិនមែនការល្បួងនាំអោយ រីកចំរើន ឬក៏ ការសាកល្បងនោះទេ ។

## ៧. បដានៃការល្បួង

ធ្វើបដានូវនិយមន័យរបស់ការល្បួងនៅខាងក្រោម និង ដាក់ព្យួរនៅក្នុងថ្នាក់រៀនធ្វើដូច្នេះអ្នកអាចលើកឡើងប្រាប់ដល់សិស្សនៅក្នុងមុខថ្នាក់ទាំងមូលសំរាប់វគ្គសិក្សានេះ ។

**ការល្បួង**

នៅពេលដែលសាតាំងព្យាយាមអោយអ្នកធ្វើខុសទៅនឹង
ច្បាប់របស់ព្រះជាម្ចាស់ដើម្បីបំពេញសេចក្តីត្រូវការ និង ចំណង់នៅក្នុងជីវិត
របស់អ្នក ។

សកម្មភាពដទៃទៀតដែលអ្នកចង់អោយសិស្សរបស់អ្នកធ្វើគឺបង្កើតបដារូបភាពមួយនៃកន្លែងខ្លះដែលសាតាំងល្បួងយើងអោយធ្វើអំពើបាប ។ ពួកគេអាចកាត់រូបភាព ឬក៏ ពាក្យមកពីការផ្សាយពាណិជ្ជកម្មក្នុងទស្សនាវដ្តី ឬក៏ កាសែត ។

## ៨. តើនរណាល្បួងយើងអោយធ្វើអំពើបាប? (៥ នាទី)

ពិភាក្សាបញ្ហាថាតើ នរណាល្បួងយើងអោយធ្វើអំពើបាប ។ អោយពួកគេប្រើអត្ថបទគម្ពីរ និង ចំលើយដែលពួកគេ បានសរសេរនៅលើសំនួរ ទី ១ និង ទី ២ នៅលើគំរោង សំរាប់ការល្បួង ។

១. តើព្រះជាម្ចាស់ល្បួងមនុស្សអោយធ្វើអំពើបាបឬទេ? (យ៉ាកុប ១:១៣)

២. តើនរណាល្បួងមនុស្សអោយធ្វើអំពើបាប? តើនរណាបានល្បួងព្រះគ្រីស្តអោយធ្វើអំពើបាប? សូមអាន ម៉ាថាយ ៤:១-១១ ។

## ៩. តើវិញ្ញាណអាក្រក់អោយអ្នកធ្វើការនោះឬ? (៣-៥នាទី)

មើលចំណុច គ ទាំងអស់ : " តើវិញ្ញាណអាក្រក់អោយអ្នកធ្វើការនោះឬ? សង្កត់អោយធ្ងន់ទៅលើសារៈសំខាន់ នៃការទទួលខុសត្រូវផ្ទាល់ខ្លួននៅក្នុងការធ្វើការសំរេចចិត្តពីរបៀបពួកគេបំពេញសេចក្តីត្រូវការ និង ចំណង់នៅក្នុងជីវិតរបស់ពួកគេ ។

អ្នកប្រហែលជាងចង់ប្រើការបង្ហាញដែលត្រូវបានផ្តល់នៅលើទំព័រ ទី ៦-៧ នៅក្នុងការណែនាំរបស់សិស្ស អំពីការ ប្រៀបធៀប " ទ្វារ " ដែលព្រះជាម្ចាស់នឹងសាតាំងដាក់នៅពីមុខអ្នក ។ សូមផ្តល់ឧទាហរណ៏អោយបានច្រើននៃទ្វារផ្សេងគ្នាដែលព្រះជាម្ចាស់ និង សាតាំងប្រហែលដាក់នៅមុខសិស្សរបស់អ្នកដើម្បីបំពេញតំរូវការពិសេស ដែលពួកគេមាន ។

**១០. តើសាតាំងល្បួងអ្នកដោយរបៀបណា? (៣-៥ នាទី)**

ចង្អុលបង្ហាញថា សាតាំងកំរនឹងមកហើយនិយាយ " សួស្តី ខ្ញុំជាសាតាំង ហើយខ្ញុំកំពុងតែល្បួងអ្នកអោយធ្វើអំពើបាប" ។ សាតាំងវាមកជួបអ្នកជាមួយនឹងគំនិតដែលវានឹងជួយបំពេញសេចក្តីត្រូវការនៅក្នុងជីវិតរបស់អ្នក ។ " អ្នកមាន តំរូវ ការ ។ អ្នកចាំបាច់ត្រូវមានសំលៀកបំពាក់ថ្មី ។ នេះគឺជាវិធីមួយដើម្បីទទួលសំលៀបំពាក់ ថ្មីនោះ ។ លួចពួកវា ទាន់ម្ចាស់ហាង កំពុងតែនិយាយជាមួយអ្នកផ្សេង ។

**ការច្នៃប្រឌិតចំនុចសំខាន់នៃការបង្រៀន**

**ប្រើមេរៀនដែលលើពីការបង្រៀននៅក្នុងថ្នាក់ទៅទៀត**

វិធីដ៏ងាយស្រួលដើម្បីជួយសិស្សរបស់អ្នកពង្រឹងគន្លឹះការបង្រៀននៃមេរៀននីមួយៗគឺបង្កើតឡើងបដាតូចៗនៅលើម៉ាស៊ីនកុំព្យូទ័ររបស់អ្នក ឬក៏ សរសេរដោយដៃ ។ ឧទាហរណ៏ :

. និយមន័យនៃការល្បួង

. ជំហាន ៦ យ៉ាងដើម្បីយកជ័យជំនះនៅលើការល្បួង

. របៀបរៀបចំសំរាប់ការល្បួង

. ខ គម្ពីរសំខាន់ ៗ ដែលទាក់ទងជាមួយការល្បួង : ២ ធីម៉ូថេ ២:២២, ទំនុកតម្កើង ៣៧:៤-៥, យ៉ាកុប ៤:៧-៨ ។ ល ។

. ឃ្លាសំខាន់ៗដូចជា ។ តើផលវិបាកអ្វីខ្លះនឹងកើតឡើង ពេលមនុស្សធ្វើតាមការល្បួង?

នៅចុងបញ្ចប់មេរៀននីមួយៗ គ្រូម្នាក់ផ្តល់អោយនូវបដាតូចៗនេះទៅដល់សិស្សណាដែលចង់បានពួកវា ។ ជារឿយៗ សិស្ស នឹងផ្ញូវវានៅក្នុងបន្ទប់ដេក, កន្លែងរៀន ឬក៏ អោយវាដល់គ្រួសាររបស់ពួកគេ ។ នៅក្នុងវិធីនេះ ការបង្រៀននៅក្នុងថ្នាក់សំខាន់ៗ បន្តពីសិស្សដល់មនុស្សដទៃទៀត ។

**១១. ការល្បួងរបស់ព្រះគ្រីស្ត(១០-១៥នាទី)**

ពិភាក្សាការល្បួងបីយ៉ាងដែលព្រះគ្រីស្តបានប្រឈមមុខ និង តំរូវការដែលព្រះគ្រីស្តផ្តល់ដើម្បីបំពេញនៅក្នុងជីវិតរបស់ទ្រង់ ។ សូមមើល ម៉ាថាយ ៤:១-១១ ។ សូមអោយសិស្សយោងទៅលើចំលើយរបស់ពួកគេសំរាប់សំនួរ ទី ៧នៅលើគំរោង ទី ១ ។

**នៅពេលដែលព្រះយេស៊ូជួបការល្បួងអោយធ្វើអំពើបាប**

ការល្បួង ៣ យ៉ាងដែលសាតាំងប្រើដើម្បីល្បួងព្រះគ្រីស្ទអោយបំពេញតំរូវការផ្សេងៗ និង បំណងនៅក្នុងជីវិតរបស់ទ្រង់ ។

**ការល្បួង ទី ១ ~ អោយថ្មក្លាយទៅជានំបុ័ង**

ម៉ាថាយ ៤:២-៤

តំរូវការ-ព្រះគ្រីស្ទទ្រង់ឃ្លានខាងរូបកាយ ។ ព្រះអង្គត្រូវការម្ហូប ។

ចំណង់-បង្ហាញថាអ្នកមានអំណាចដើម្បីបំពេញតំរូវការនេះនៅក្នុងជីវិតរបស់អ្នក ។ បង្ហាញថា អ្នកអាចសំដែងនូវការអស្ចារ្យបាន ។

**ការល្បួង ទី ២ ~ អោយលោតទម្លាក់ខ្លួនពីកំពូលព្រះវិហារ**

ម៉ាថាយ ៤:៥-៧

ចំណង់-បង្ហាញថា អ្នកទុកចិត្តព្រះជាម្ចាស់ ...

ចំណង់-បង្ហាញថា ព្រះជាម្ចាស់គាំទ្រអ្នក ។

**ការល្បួង ទី ៣ ~ សាតាំងផ្តល់អោយព្រះយេស៊ូគ្រប់គ្រងពិភពលោក**

ម៉ាថាយ ៤:៨-១០

បន្ទាប់ពីមើលឃើញនគរទាំងមូលរបស់ពិភពលោក សាតាំងផ្តល់ជូនទាំងអស់ដល់ព្រះគ្រីស្តប្រសិនបើទ្រង់នឹងក្រាបថ្វាយបង្គំដល់សាតាំង ។

ចំណង់-បំពេញតាមចំណង់អារក្សសាតាំងក្នុងការគ្រប់គ្រង( ត្រួតត្រា) ពិភពលោកតាមផ្លូវងាយស្រួល( ផ្ទុយទៅនឹងវិធីរបស់ព្រះជាម្ចាស់ដែលទីបញ្ចប់នាំទៅរកការសុគតដ៏ឈឺចាប់នៅលើឈើឆ្កាង) ។

## ១២. ភាពខុសគ្នារវាងតំរូវការ និង ការល្បួង (៥-១៥ នាទី)

ធ្វើអោយប្រាកដថាសិស្សរបស់អ្នកចាប់ផ្តើមយល់ដឹងភាពខុសគ្នារវាងការល្បួង និង តំរូវការ ។ តំរូវការគឺពិតប្រាកដ ។ ប្រសិនបើមនុស្សមិនបានញ៉ាំទេ គាត់មានតំរូវការខាងរាងកាយសំរាប់ម្ហូបអាហារ ។ ការល្បួងរបស់អារក្សសាតាំង អោយលួចម្ហូបខ្លះគឺជាផ្លូវមួយដើម្បីបំពេញតំរូវការ ។ រាល់ការល្បួងទាំងអស់គឺត្រូវបានចងជាប់ទៅនឹងតំរូវការ ឬក៏ ចំណង់ ដែលអ្នកមាន ។ ជួនកាល យើងមិនយល់ដឹងពីតំរូវការរបស់យើង ។

ឥឡូវនេះប្រហែលជាពេលវេលាដ៏ល្អដើម្បីពិភាក្សានៃតំរូវការនៅលើទំព័រ ទី ៧ និង ទី ៨នៃការណែនាំរបស់សិស្ស ។ ចង្អុលបង្ហាញអោយឃើញថា យើងទាំងអស់គ្នាមានតំរូវការទាំងនេះ ។ សូមផ្តល់ឧទាហរណ៍អោយច្រើននៃការល្បួង និង តំរូវការដ៏ជាក់លាក់ ។ បង្ហាញរបៀបព្រះជាម្ចាស់នឹងជួយសិស្សរបស់ អ្នកអោយបំពេញតំរូវការទាំងនេះនៅក្នុងជីវិតរបស់ ពួកគេ ។ សាតាំងនឹងជួយព្យាយាមជួយបំពេញតំរូវការរបស់ពួកគេផងដែរ ។

## ១៣. យល់ដឹងអំពីភាពខុសគ្នារវាងតំរូវការ និង ចំណង់ (៣-៥នាទី)

មានសិស្សជាច្រើនមានការលំបាកយល់ដឹងពីភាពខុសគ្នារវាងតំរូវការ និង ចំណង់ ។ សូមអោយយើងទៅមើល បញ្ជីនៃតំរូវការដែលចាប់ផ្តើមនៅទំព័រ ទី ៧ នៃការណែនាំរបស់សិស្ស និង យកប្រភេទតំរូវការជាច្រើន និង អោយពួកគេ ផ្តល់ឧទាហរណ៍ដល់អ្នកនៃតំរូវការ និង ចំណង់ដែលទាក់ទងទៅនឹងតំរូវការនិងចំណង់នីមួយៗ ។

ឧទាហរណ៍ អ្នកត្រូវការម្ហូបអាហារ ។ ប៉ុន្តែអ្នកប្រហែលជាមានចំណង់នំល្វដ៏ធំមួយវិញ ។ អ្នកត្រូវការអាវរងារនៅក្នុងខែរងារ ជាពិសេសពេលមានធ្លាក់ព្រិលនៅខាងក្រៅ ។ ប៉ុន្តែអ្នកប្រហែលជាមានចំណង់ចង់បាន អាវរងារ ៧ ទៅ ៨ អាវ ។ អ្នកប្រហែលជាចង់បានអាវរងាររោមសត្វដ៏វែងមួយ ។

អ្នកត្រូវការមានមិត្តភ័ក្តិ ប៉ុន្តែអ្នកប្រហែលជាមានចំណង់ចង់បានមនុស្សពិសេសណាមួយដូចមិត្តរបស់អ្នកជាពិសេស បើគាត់ជាអ្នកមាន ឬក៏ ស្រស់សង្ហា!

វាមានប្រយោជន៏សំរាប់សិស្សរបស់អ្នកអោយសរសេរនៅនិយមន័យនៃតំរូវការ និង ចំណង់ ។ សូមអោយពួកគេផ្តល់គំនិត របស់គេដល់អ្នកនៅអ្វីដែលត្រូវបានរួមបញ្ចូលនៅក្នុងនិយមន័យទាំងនេះ ។ នេះគឺជានិមយន័យដែលត្រូវបានផ្តល់ជូន ។

**តំរូវការ**- អ្វីមួយដែលតំរូវអោយយើងមានដើម្បីពិសោធន៍ និង ទ្រទ្រង់ជីវិតដើម្បីអោយមានសក្តានុភាពពេញលេញ

**ចំណង់** - អ្វីមួយដែលយើងចង់បាន, ប៉ុន្តែបើមិនមានកិច្ចការនោះក៏មិនអីដែរ ។

## ១៤. របៀបសាតាំងធ្វើអោយចាប់អារម្មណ៏ចំពោះតំរូវការ និង ចំណង់របស់អ្នក

ចង្អុលបង្ហាញថា ការល្បួងមួយប្រហែលជាសាតាំងចង់ជួយអ្នកអោយបំពេញតំរូវការ ពីរ ឬក៏ បី និង ក៏បំពេញ នៅចំណង់នៅក្នុងជីវិតរបស់អ្នក ។ ឧទាហរណ៍ ការល្បួងទី ១ របស់សាតាំងចំពោះព្រះគ្រីស្តនៅក្នុងទីរហោឋានគឺផ្តោតទៅលើ តំរូវការរបស់ព្រះគ្រីស្តសំរាប់ម្ហូប ។ សាតាំងក៏ព្យាយាមអោយ ព្រះគ្រីស្តជឿផង

ដែរថា ព្រះអង្គចាំបាច់ត្រូវតែបង្ហាញថា ព្រះអង្គគឺជាបុត្រារបស់ព្រះជាម្ចាស់ ។ សាតាំងព្យាយាមបង្កើតនៅចំណង់នៅក្នុងព្រះគ្រីស្ទដើម្បីបង្ហាញការពិតនេះ ។

សាតាំងប្រហែលជាព្យាយាមធ្វើអោយអ្នកជឿថាអ្វីដែលជាចំណង់នោះគឺជាតំរូវការនៅក្នុងជីវិតរបស់អ្នក។ " អ្នកពិតជាត្រូវការនៅអាវរងារោមសត្វថ្មីនោះណាស់, ឬក៏ ឡានថ្មី, ឬក៏ មិនភ័ក្តិរបស់អ្នកមិនចូលចិត្តអ្នក ។"

វិធីមួយទៀតដែរ សាតាំងព្យាយាមអោយអ្នកឃ្លាតចេញពីផែនការរបស់ព្រះជាម្ចាស់សំរាប់អ្នកគឺបំពេញតំរូវការ ឬក៏ ចំណង់របស់អ្នក ដែលកិច្ចការនោះវាមិនស្របទៅតាមពេលវេលារបស់ព្រះជាម្ចាស់ ។ " ការបំពេញចិត្តភ្លាមៗ " គឺត្រូវ បានអនុវត្តជាធម្មតានៅក្នុងជីវិតរបស់មនុស្សដែលជាប់ទាក់ទងជាមួយនឹងការញៀន ។ ប៉ុន្តែវាក៏អាចជាបញ្ហាផងដែរនៅក្នុងជីវិតរបស់មនុស្ស ។ " ការបំពេញចិត្តភ្លាមៗ " អាចជាការល្បួងដែលត្រូវ បានចងភ្ជាប់ទៅនឹងតំរូវការដែលការនេះគឺជាការល្បួងទី១ ដែលព្រះគ្រីស្ទបានប្រឈមមុខនៅក្នុងម៉ាថាយ ៤:២-៤ ។

## ១៥. តើសាតាំងបានល្បួងអេវ៉ាដោយរបៀបណា? (៥-១០នាទី)

អ្នកប្រហែលជាអោយសិស្សពិភាក្សាពីតំរូវការ (នៅក្នុងស្ថានភាពពិត, ចំណង់)ដែលសាតាំងបាននិយាយត្រូវបាន បំពេញប្រសិនបើអេវ៉ាបានញ៉ាំផ្លែឈើនៅក្នុងសួនច្បារអេដែន ។ សូមអោយពួកគេអាន កំណើតពិភពលោក ជំពូក ៣ ដើម្បី រកអោយឃើញវិធីពិតប្រាកដដែលសាតាំងបាន និយាយប្រាប់អេវ៉ាថា នាងនឹងទទួលផលប្រយោជន៍ប្រសិនបើនាងអេវ៉ាធ្វើអ្វី ដែលសាតាំងប្រាប់អោយនាងធ្វើ ។

## ១៦. សូមមើលនៅការល្បួងរបស់យើង (៥-១៥នាទី)

សូមបង្ហាញអោយបានច្រើននៃការល្បួងដែលអ្នកឬក៏ កូនសិស្សរបស់អ្នកបានប្រឈមមុខនៅពេលថ្មីៗនេះ។ សូម អោយសិស្សផ្តល់នូវឧទាហរណ៍ខ្លះៗដែលពួកគេបានសរសេរនៅក្នុងគំរោងទី ២ ។ ពិភាក្សាតំរូវការ និងចំណង់ដែលសាតាំង ល្បួងមនុស្សអោយបំពេញទៅតាមផ្លូវរបស់វា ។ អ្នកប្រហែលជាចង់បញ្ជាក់អោយឃើញតើច្បាប់មួយណារបស់ព្រះជាម្ចាស់ដែល អ្នកនឹងធ្វើខុសប្រសិនបើអ្នកបំពេញតំរូវការនេះតាមវិធីរបស់សាតាំង ។

## ១៧. ការអនុវត្តន៍ផ្ទាល់ខ្លួន(៥-១០នាទី)

ផ្តោតទៅលើការអនុវត្តន៍ផ្ទាល់ខ្លួននៅលើការរៀនពីរបៀបទទួលស្គាល់តំរូវការ ឬក៏ ចំណង់ដែលសាតាំងកំពុងតែព្យាយាមអោយអ្នកបំពេញនៅតំរូវការ ឬក៏ ចំណង់នោះនៅពេលដែលវាល្បួងអ្នកអោយធ្វើអំពើបាប ។ ប្រសិនបើពួកគេមិន បានធ្វើកិច្ចការនេះនៅឡើយទេ សូមអោយសិស្សបំពេញចំលើយនៅសំនួរ ទី ៣ និង ទី ៤នៅក្នុងឧទាហរណ៍ទាំង បីដែលពួក គេបានដាក់នៅក្នុងគំរោង ទី ២ ។ មុនដំបូង អ្នកប្រហែលជាចង់អោយសិស្សស្វែងរកចំលើយដោយខ្លួនឯងសិន បន្ទាប់មក ទើបអោយពួកគេចូលជាក្រុម បី ឬក៏ បួននាក់ដើម្បីពិភាក្សាចំលើយរបស់ពួកគេ ។

## ១៨. កិច្ចការត្រូវធ្វើ

ក. ដាក់ពិន្ទុ គំរោងទី ១

ខ. សូមត្រួតពិនិត្យមើលថាពួកគេបានបញ្ចប់គំរោង ទី ២ ។ ពួកគេនឹងត្រូវការគំរោងទី ២ នេះដើម្បីអាច បំពេញគំរោងទី ៥ ដែលនឹងផុតកំណត់នៅថ្នាក់រៀនផ្នែក ទី ៣ ។ អ្នកប្រហែលជាចង់ត្រួតពិនិត្យគំរោង ទី ២ និងប្រគល់អោយគេវិញនៅវគ្គថ្នាក់រៀនពេលក្រោយ ។

គ. ពន្យល់គំរោង ទី ៤ ។ ដូចដែលអ្នកបានមើលឃើញនៅកិច្ចការនេះ សិស្សមានជំរើសជាច្រើនដែល ពួកគេអាចជ្រើសរើស ។ ទោះជាយ៉ាងណាក៏ដោយអ្នកប្រហែល ជាចង់ធ្វើអោយប្រាកដថា គ្រប់ទាំង សិស្ស ទាំងអស់មិនជ្រើសរើសដូចគ្នា ជាពិសេសប្រសិនបើអ្នកចង់ប្រើកិច្ចការទាំងនេះនៅក្នុង ការពិភាក្សា នៅក្នុង ថ្នាក់នៅក្នុងមេរៀនមុន ។ សូមមើលគំរោងផែនការមេរៀន ទី ២, ចំនុច ទី ៤ នៅលើទំព័រ ទី ១១ ។

ឃ. ពន្យល់គំរោងទី ៣ នោះ " តំរូវការ និង ចំណង់របស់ខ្ញុំ " ត្រូវបានរៀបចំឡើងជាប់ទៅនឹងមេរៀនដែល ទើបតែបានបញ្ចប់ ។ ពួកគេមានសេរីភាពប្រើការកត់សំគាល់នៅក្នុងថ្នាក់ និង ការណែនាំរបស់សិស្ស ដើម្បីបំពេញការងាររបស់ពួកគេនៅលើគំរោងនេះ ។ អ្នកនឹងចាំបាច់ត្រូវសំរេចចិត្តនៅលើអ្វីដែល អ្នកចង់ អោយពួកគេធ្វើជាមួយនឹង " សំនួរសំរាប់ការសិក្សាបន្ថែម " នៅលើទំព័រ ទី ២ នៃគំរោង ។ តើអ្នកចង់ អោយពួកគេសរសេរចំលើយសំរាប់សំនួរទាំងនេះនៅលើក្រដាសផ្សេង និង ប្រគល់កិច្ចការនេះអោយអ្នក ដើម្បីដាក់ពិន្ទុឬ?

## ១៩. ការវាយតំលៃមេរៀន

សូមបង្ហាញគំនិតរបស់អ្នកសំរាប់ធ្វើអោយមេរៀននេះកាន់តែប្រសើរឡើង ។ តើផ្នែកណាដែលល្អបំផុត? តើចំនុចណាដែលពិបាកបំផុតសំរាប់សិស្សយល់ដឹង? តើចំនុចមួយណាមើលទៅវាមានប្រយោជន៍ដល់សិស្សរបស់ អ្នក?

# មេរៀន ទី ២

# ការយកជ័យជំនះលើការល្បួង

**១. សេចក្តីពិតសំខាន់ៗនៅក្នុងព្រះគម្ពីរ**

ខ្ញុំចាំបាច់ត្រូវតែចងចាំ និង ប្រើគំរូនៃព្រះគម្ពីរសំរាប់ឆ្លើយតបទៅនឹងការល្បួង ។

**២. ខគម្ពីរសំខាន់ : អេភេសូ ៦:១៣**

ដូច្នេះសូមប្រើគ្រប់ទាំងសាស្ត្រាវុធរបស់ព្រះជាម្ចាស់ដើម្បីតទល់នឹងសត្រូវពេលណាដែលវាវាយប្រហារយើង និង នៅពេលដែលកិច្ចការនោះចប់ អ្នកនឹងនៅតែឈរជាប់ដដែល ។

**៣. សំភារៈសិក្សាយោងរបស់សិស្ស**

ទំព័រ ទី ១១-១៦នៅក្នុងការណែនាំរបស់សិស្សជាប់ជាមួយនឹងមេរៀននេះ ។ គំរោងទី ៤នៅក្នុងការណែនាំការសិក្សានឹងត្រូវបានប្រើនៅក្នុងមេរៀននេះផងដែរ ។

**៤. ការចាប់ផ្តើមមេរៀន : " តើអ្នកឈរនៅត្រង់កន្លែងណា? " (៥-១០នាទី)**

ចាប់ផ្តើមថ្នាក់រៀនដោយពិភាក្សាបញ្ហាដែលត្រូវបានលើកឡើងនៅលើទំព័រ ទី ១១-១២ នៅក្នុងការណែនាំរបស់សិស្ស ចំណុច ក. " តើអ្នកឈរនៅត្រង់កន្លែងណា? " គូររូបភាពជញ្ជាំង ឬក៏ របងនៅលើក្តារខៀន ឬក៏ នៅលើម៉ាស៊ីនបញ្ចាំងស្លាយរបស់អ្នក ដើម្បីបង្ហាញការសំរេចចិត្តដែលគ្រប់គ្រីស្ទបរិស័ទកំពុងតែប្រឈមមុខ ។ នៅម្ខាងក្តារខៀនសរសេរ " ប្តេជ្ញាយ៉ាងម៉ឺងម៉ាត់ដើម្បីដើរតាមផ្លូវរបស់ព្រះជាម្ចាស់ " និងម្ខាងទៀតសរសេរ " ប្តេជ្ញាយ៉ាងម៉ឺងម៉ាត់ដើម្បីដើរតាមផ្លូវរបស់អារក្សសាតាំង ។ "

ឥឡូវសូមបង្ហាញមនុស្សដែលនៅក្នុងព្រះគម្ពីរដែលល្បីឈ្មោះនៅលើរូបភាពនេះ ។ អ្នកប្រហែលជាចង់អោយសិស្សបង្ហាញមនុស្សដែលពួកគេបានសិក្សានៅពេលដែលពួកគេធ្វើនៅគំរោង ទី ៤ ។ ឧទាហរណ៍ នៅក្នុងសញ្ញាចាស់ របស់លោក យ៉ូសែប និង លោក ដានីអែល និង មិត្តទាំងបីរបស់គាត់អាចត្រូវបានដាក់នៅម្ខាងដែលសរសេរថា *" ប្តេជ្ញាយ៉ាងម៉ឺងម៉ាត់ដើម្បីដើរតាមផ្លូវរបស់ព្រះជាម្ចាស់ "*

យេសេបេល និង អេហាប់នៅក្នុងព្រះគម្ពីរសញ្ញាចាស់ក៏នឹងត្រូវដាក់ក្នុងកន្លែងផ្ទុយពីគ្នាដែរ ។ យ៉ូដាសប្រហែលជានៅលើរបងជាមួយនឹងសញ្ញាព្រួញបែរទៅតាមផ្លូវរបស់អារក្សសាតាំង ។ លោកពេត្រុស នៅពេលគេឆ្កាងព្រះគ្រីស្ទបានបែរទៅរកផ្លូវរបស់អារក្សសាតាំង ប៉ុន្តែបន្ទាប់មកគាត់បានកែប្រែ និង បែរត្រឡប់មកផ្លូវរបស់ព្រះជាម្ចាស់វិញ ។

ចង្អុលបង្ហាញថាពួកគេមិនអាចដើរនៅលើរបងសំរាប់ជីវិតរបស់ពួកគេនោះទេ ។ គ្រីស្តបរិស័ទ

ម្នាក់ៗត្រូវតែធ្វើការសំរេចចិត្តដើរតាមព្រះជាម្ចាស់ឬក៏ ដើរតាមអារក្សសាតាំង ។ សូមសង្កត់អោយធ្ងន់នៅលើចំណុចសំខាន់នៃការសំរេចចិត្តនេះនៅក្នុងទំនាក់ទំនងខ្លួនដើម្បីអោយមានជ័យជំនះនៅក្នុងការយកឈ្នះលើការល្បួងអោយប្រព្រឹត្តអំពើបាប ។

**៥. តើមនុស្សនៅក្នុងព្រះគម្ពីរបានប្រឈមមុខទៅនឹងការល្បួងដោយរបៀបណា? (១០-១៥ នាទី)**

ពិភាក្សាចំពោះមនុស្សផ្សេងៗគ្នានៅក្នុងព្រះគម្ពីរដែលត្រូវបានគេរាយបញ្ជីនៅលើគំរោង ទី ៤ ។ សូមមើលពីរបៀបពួកគេតទល់ការល្បួងដែលពួកគេបានប្រឈមមុខ ។ ព្យាយាមកំណត់មូលហេតុហេតុអ្វី មនុស្សបរាជ័យប្រសិនបើគាត់ធ្វើតាមការល្បួង ។

**៦. ជំហាន ៦ យ៉ាង ដើម្បីយកជ័យជំនះលើការល្បួង(១០-១៥ នាទី)**

ឥឡូវនេះសូមបង្ហាញអោយលឿននៅ ៦ ជំហានដើម្បីយកជ័យជំនះលើការល្បួង ។ បង្ហាញប្រាប់ថានេះគឺជាគំរូដែលពួកគេអាចប្រើនៅក្នុងការឆ្លើយតបចំពោះការល្បួងពួកគេអោយធ្វើអំពើបាប ។

ជំហាន ៦ យ៉ាងដើម្បីយកជ័យជំនះលើការល្បួង

១. ទទួលស្គាល់ថា អ្នកជួបការល្បួង

២. និយាយថា ទេ ចំពោះការល្បួង

៣. ចាប់ផ្តើមនិយាយជាមួយព្រះជាម្ចាស់

៤. សួរខ្លួនឯង " តើតំរូវការអ្វីដែលសាតាំងកំពុងតែព្យាយាមបំពេញតំរូវការរបស់ខ្ញុំ? "

៥. ស្វែងរកផ្លូវរបស់ព្រះជាម្ចាស់ដើម្បីចេញអោយផុតពីការល្បួងនេះ

៦. បង្កើតគោលដៅដែលនឹងជួយបំពេញតំរូវការរបស់អ្នកតាមផ្លូវរបស់ព្រះជាម្ចាស់

បន្ទាប់ពីអ្នកបានណែនាំអោយស្គាល់យ៉ាងសង្ខេបនៅបញ្ជីទាំងមូលនៅលើទំព័រ ទី ១៣នៅក្នុង សៀវភៅណែនាំរបស់សិស្ស ផ្តល់ឧទាហរណ៍ពីរបៀបដែលអ្នកអាចប្រើគំរូនេះជាមួយនឹងការល្បួងជាក់លាក់ណាមួយ ។

បន្ទាប់មកត្រឡប់ទៅវិញ និង ពិភាក្សាចំនុចនីមួយៗអោយបានលំអិត ។ សូមមើលទំព័រ ទី ១៣-១៦នៅក្នុងសៀវភៅណែនាំរបស់សិស្សសំរាប់ព័ត៌មានបន្ថែមនៅលើជំហាននីមួយៗ ។ សូមព្យាយាមផ្តល់ឧទាហរណ៍ជាច្រើនពីរបៀបដែលពួកគេអាចប្រើចំនុចនីមួយៗជាមួយនឹងការល្បួងផ្សេងៗគ្នា ។ អ្នកអាចអោយសិស្សផ្តល់នូវឧទាហរណ៍ខ្លះនៃការល្បួងពីកិច្ចការដែលពួកគេបានធ្វើនៅលើគំរោង ទី ២ ។

**៧. បែងចែកអោយបានច្បាស់លាស់រវាងតំរូវការ និង ការល្បួង**

ក្នុងការពិភាក្សាការល្បួងខុសៗគ្នា សូមព្យាយាមបែងចែកអោយដាច់ពីការល្បួង និងតំរូវការធ្វើដូច្នេះពួកគេអាចមើលឃើញពីរបៀបគំរូខាងព្រះគម្ពីរនេះនឹងជួយពួកគេអោយយកជ័យជំនះលើការល្បួង ហើយទន្ទឹមនឹងពេលវេលានោះដែរ បំពេញសេចក្តីត្រូវការដែលសាតាំងចង់អោយយើងភ្លក់រសជាតិ ។

អ្នកអាចចង្អុលបង្ហាញផងដែរថាតើច្បាប់មួយណារបស់ព្រះជាម្ចាស់ដែលមនុស្សនឹងធ្វើខុស ប្រសិនបើពួកគេធ្វើតាមការល្បួង ។

## ៨. ប្រសិនបើខ្ញុំជាសកម្មភាពរបស់ព្រះជាម្ចាស់ ឬក៏ របស់អារក្សសាតាំង

សំរាប់សកម្មភាពពេលក្រោយនេះ អ្នកត្រូវតែចែកថ្នាក់ជាក្រុមតូចៗដែលមានគ្នាពី ២ ទៅ ៤នាក់ក្នុងមួយក្រុម ។ ព្យាយាមធ្វើអោយក្រុមមានចំនួនគូ (២, ៤, ៦, ។ល។)

ក. ផ្ដល់ជូនក្រុមនីមួយៗនូវសន្លឹកណែនាំនៅលើ " ប្រសិនបើខ្ញុំជាព្រះជាម្ចាស់ឬក៏ ... សារតាំង " សូមមើលទំព័រ ទី ១៦ និង ១៧សំរាប់សន្លឹកណែនាំទាំងនេះ ។ ពន្យល់នូវសេចក្ដីណែនាំ និង បន្ទាប់មកអោយ ៥ នាទីក្នុងការ បំពេញកិច្ចការរបស់ពួកគេ ។

ខ. អោយក្រុមនីមួយៗធ្វើរបាយការណ៏ដល់ថ្នាក់ទាំងមូលពីរបៀបពួកគេអាចធ្វើអោយគ្រីស្ដបរិសទ័ទប់ទល់នឹងនឹងការល្បួង ឬក៏ ធ្វើតាមការល្បួង ។

គ. ណែនាំសិស្សដែលនៅសល់ក្នុងថ្នាក់ទាំងអស់អោយស្ដាប់ការបង្ហាញរបស់ក្រុមនីមួយៗដោយចាត់ទុកថាពួកគេកំពុងតែជួបប្រទះការល្បួង ។

ឃ. បន្ទាប់ពីអ្នកបានស្ដាប់ទាំងសងខាងនៃការល្បួងមួយហើយ សូមអោយសិស្សពិភាក្សាថាតើខាងមួយណាដែលអោយជឿជាក់បាននោះ-ខាងព្រះជាម្ចាស់ ឬក៏ ខាងអារក្សសាតាំង ? អោយពួកគេពន្យល់ផ្នែកមួយណានៃការប្រកែកគ្នានេះដែលគួរអោយជឿជាក់បាន និង មូលហេតុអ្វី ។ អ្នកអាចពិភាក្សាបានផងដែរថាតើហេតុអ្វីបានជាការប្រកែកគ្នាខ្លះមិនគួរជឿជាក់បាន ។

ង. អ្នកអាចឱ្យសិស្សចែកចាយនូវគំនិតបន្ថែមពីរបៀបការចូលទៅជិតព្រះជាម្ចាស់ ឬក៏ អារក្សសាតាំងអាចត្រូវបានកែលំអរ ។ សូមចង្អុលបង្ហាញនៅក្នុងពេលវេលាពិភាក្សាទាំងខាងព្រះជាម្ចាស់ និង ខាងអារក្សសាតាំងដែលអាចផ្ដោតការយកចិត្តទុកដាក់ចំពោះសេចក្ដីត្រូវការ ឬក៏ ចំណង់ដែលជាប់ទាក់ទងជាមួយនឹងការល្បួង ។

## ៩. ការអនុវត្តន៏ផ្ទាល់ខ្លួន

សំរាប់ការអនុវត្តន៏ផ្ទាល់នៅថ្ងៃនេះ អោយសិស្សទន្ទេញចាំនូវគំរូជំហានទាំង ៦ដើម្បីប្រើនៅពេលឆ្លើយតបចំពោះការល្បួង (សូមមើលទំព័រ ទី ១៣នៃសៀវភៅណែនាំរបស់សិស្ស ) ។ ប្រាប់ពួកគេថានៅពេលណាពួកគេនឹងមានធ្វើសំនួរខ្លីៗនៅលើកិច្ចការនេះ ។ សូមមើលបញ្ជីកិច្ចការត្រូវធ្វើនៅក្នុងថ្នាក់សំរាប់កាលបរិច្ឆេតនៃសំនួរខ្លីនេះ ។

លើកទឹកចិត្តពួកគេអោយចាប់ផ្ដើមប្រើគំរូនៃការឆ្លើយតបថ្ងៃនេះ ។ សង្កត់ទៅលើសារៈសំខាន់នៃការចាប់ផ្ដើមជាមួយនឹងជំហាននីមួយៗ ។ ប្រសិនបើពួកគេពិបាកក្នុងការចង់ចាំ សូមប្រើជំហានទីមួយ និង លើកទឹកចិត្តពួកគេយ៉ាងហោចណាស់សរសេរចូរនូវរាល់ការល្បួងនានា ដែលពួកគេបានជួបប្រទះនៅថ្ងៃនេះ ។

## ១០. កិច្ចការត្រូវធ្វើ

ក. នៅពេលបញ្ចប់ថ្នាក់រៀន សូមផ្តល់សំនួរខ្លីៗនៅលើ ១ កូរិនថូស ១០:១៣ ។

ខ. ដាក់ពិន្ទុ គំរោង ទី ៣ និង ៤

គ. ប្រសិនបើអ្នកបានប្រមូល គំរោង ទី ២ នៅចុងបញ្ចប់ថ្នាក់រៀន ។ សូមផ្តល់ឱ្យសិស្សវិញនៅថ្ងៃនេះ ។ ពន្យល់ពីរបៀបគំរោង ទី ៥ ស៊ីគ្នាជាមួយនឹងគំរោង ទី ២ ។

ឃ. ប្រសិនបើអ្នកមិនបានធ្វើការសំរេចចិត្ត អ្នកចាំបាច់ត្រូវតែអោយសិស្សរបស់អ្នកស្គាល់គំរោង មួយណាពួកគេចាំបាច់ត្រូវបំពេញសំរាប់មេរៀនលើកក្រោយ ។ ប្រសិនបើអ្នករៀបចំផែនការប្រើគំរោង ទី ៦ និង ទី ៧ នៅក្នុងថ្នាក់រៀនលើកក្រោយ បន្ទាប់មកប្រាប់ពួកគេថា ពួកគេអាចបំពេញកិច្ចការអោយចប់សព្វគ្រប់ទាន់ពេលវេលា ។

## ១១. ការវាយតំលៃមេរៀន

សូមបង្ហាញគំនិតរបស់អ្នកសំរាប់ធ្វើអោយមេរៀននេះកាន់តែប្រសើរឡើង ។ តើផ្នែកណាដែលល្អបំផុត? តើចំនុចណាដែលពិបាកបំផុតសំរាប់សិស្សយល់ដឹង? តើចំនុចមួយណាមើលទៅវាមានប្រយោជន៍ដល់សិស្សរបស់អ្នក?

# ការល្បែង

## មេរៀន ទី ២

## កំណត់សំគាល់ការសិក្សានាំមុខ

### ប្រសិនបើខ្ញុំជាសតម្មតាពរបស់ព្រះជាម្ចាស់ ឬក៏ របស់អារក្សសាតាំង

សេចក្តីណែនាំសំរាប់ការប្រើសកម្មភាពនេះត្រូវបានផ្តល់ជូននៅក្នុងចំនុច ទី ៨ នៅទំព័រ ទី ១៣ នៃសៀវភៅណែនាំនេះ ។ អ្នកនឹងត្រូវធ្វើកិច្ចការខាងក្រោមមុននឹងថ្នាក់រៀនចាប់ផ្តើម ។

១. ចតចំលងសេចក្តីណែនាំនីមួយៗនៅលើសន្លឹកក្រដាសផ្សេងៗគ្នា ។ អ្នកនឹងផ្តល់ឱ្យក្រុមនីមួយៗនូវតែផ្នែកម្ខាងប៉ុណ្ណោះ ។ ក្រុមនឹងធ្វើកិច្ចការនៅលើតែផ្នែក " ប្រសិនបើខ្ញុំជាព្រះជាម្ចាស់ " ម្ខាងនៃការល្បែង ។ ក្រុមផ្សេងទៀតនឹងធ្វើកិច្ចការនៅលើផ្នែក " ប្រសិនបើខ្ញុំជាអារក្សសាតាំង " ម្ខាងនៃការល្បែងនោះ ។

២. សូមកំណត់ថា ការល្បែងមួយណាដែលអ្នកប្រើដំបូងនៅក្នុងថ្នាក់រៀនរបស់អ្នក ។ ប្រសិនបើថ្នាក់ដែលអ្នកកំពុងតែបង្រៀនមិនប្រឈមមុខទៅនឹងការល្បួងពិសេសទាំងនេះ នោះត្រូវតែជំនួសនូវឧទាហរណ៍ទាំងនេះ ។ សូមប្រើការល្បួងដែលមនុស្សភាគច្រើននៅក្នុងថ្នាក់របស់អ្នកជួបប្រទះជាញឹកញាប់ ។

### ១. ប្រសិនបើខ្ញុំជាព្រះជាម្ចាស់

ប្រសិនបើខ្ញុំជាព្រះជាម្ចាស់ នេះគឺជាវិធីដែលខ្ញុំនឹងប្រើដើម្បីធ្វើអោយអ្នកមិនបន្ទុំក្នុងការប្រលងនៅក្នុងសាលារបស់អ្នក ។

**សេចក្តីណែនាំសំរាប់ក្រុមរបស់អ្នក** : សូមសរសេរចូលកិច្ចការ ៥ -១០ ដែលអ្នកនឹងនិយាយ ឬក៏ ធ្វើចំពោះមនុស្សនេះដើម្បីព្យាយាមអោយគាត់ជឿតាមដំបូន្មានរបស់អ្នក ។

### ២. ប្រសិនបើខ្ញុំជាអារក្សសាតាំង

ប្រសិនបើខ្ញុំជាព្រះជាម្ចាស់ នេះគឺជាវិធីដែលខ្ញុំនឹងប្រើដើម្បីធ្វើអោយអ្នកមិនបន្ទុំក្នុងការប្រលងនៅក្នុងសាលារបស់អ្នក ។

**សេចក្តីណែនាំសំរាប់ក្រុមរបស់អ្នក** : សូមសរសេរចូលកិច្ចការ ៥ -១០ ដែលអ្នកនឹងនិយាយ ឬក៏ ធ្វើចំពោះមនុស្សនេះដើម្បីព្យាយាមអោយគាត់ជឿតាមដំបូន្មានរបស់អ្នក ។

### ៣. ប្រសិនបើខ្ញុំជាព្រះជាម្ចាស់

ប្រសិនបើខ្ញុំជាព្រះជាម្ចាស់ នេះគឺជាវិធីដែលខ្ញុំនឹងប្រើដើម្បីធ្វើអោយអ្នកជឿថាការមិនជក់បារី ធ្វើអោយមិត្តភិក្តិរបស់អ្នកទទួលស្គាល់អ្នក ។

**សេចក្ដីណែនាំសំរាប់ក្រុមរបស់អ្នក:** សូមសរសេរ ៥-១០ កិច្ចការដែលអ្នកនឹងនិយាយ ឬក៏ ធ្វើចំពោះមនុស្សនេះ ដើម្បីធ្វើយ៉ាងម៉េចអោយគាត់ជឿជាក់ដើរតាមដំបូន្មានរបស់អ្នក ។

### ៤. ប្រសិនបើខ្ញុំជាអារក្សសាតាំង

ប្រសិនបើខ្ញុំជាអារក្សសាតាំង នេះគឺជាវិធីដែលខ្ញុំនឹងប្រើដើម្បីធ្វើអោយអ្នកជឿថាការជក់បារី ធ្វើអោយមិត្តភិក្ដិរបស់អ្នកទទួលស្គាល់អ្នក ។

**សេចក្ដីណែនាំសំរាប់ក្រុមរបស់អ្នក:** សូមសរសេរ ៥-១០ កិច្ចការដែលអ្នកនឹងនិយាយ ឬក៏ ធ្វើចំពោះមនុស្សនេះ ដើម្បីធ្វើយ៉ាងម៉េចអោយគាត់ជឿជាក់ដើរតាមដំបូន្មានរបស់អ្នក ។

### ៥. ប្រសិនបើខ្ញុំជាព្រះជាម្ចាស់

ប្រសិនបើខ្ញុំជាព្រះជាម្ចាស់ នេះគឺជាវិធីដែលខ្ញុំនឹងធ្វើអោយអ្នកស្ដាប់បង្គាប់ឪពុកម្ដាយរបស់អ្នក ។

**សេចក្ដីណែនាំសំរាប់ក្រុមរបស់អ្នក:** សូមសរសេរ ៥-១០ កិច្ចការដែលអ្នកនឹងនិយាយ ឬក៏ ធ្វើចំពោះមនុស្សនេះ ដើម្បីធ្វើយ៉ាងម៉េចអោយគាត់ជឿជាក់ដើរតាមដំបូន្មានរបស់អ្នក ។

### ៦. ប្រសិនបើខ្ញុំជាមារសាតាំង

ប្រសិនបើខ្ញុំជាមារសាតាំង នេះគឺជាវិធីដែលខ្ញុំនឹងធ្វើអោយអ្នកមិនស្ដាប់បង្គាប់ឪពុកម្ដាយរបស់អ្នក ។

**សេចក្ដីណែនាំសំរាប់ក្រុមរបស់អ្នក:** សូមសរសេរ ៥-១០ កិច្ចការដែលអ្នកនឹងនិយាយ ឬក៏ ធ្វើចំពោះមនុស្សនេះ ដើម្បីធ្វើយ៉ាងម៉េចអោយគាត់ជឿជាក់ដើរតាមដំបូន្មានរបស់អ្នក ។

# មេរៀន ទី ៣

# ការរៀបចំខ្លួនសំរាប់ការល្បួង

## ១. សេចក្តីពិតសំខាន់ៗនៅក្នុងព្រះគម្ពីរ

ជាគ្រីស្ទបរិស័ទ ខ្ញុំចាំបាច់ត្រូវតែរៀបចំខ្លួនខ្ញុំផ្ទាល់ធ្វើដូច្នេះខ្ញុំអាចយកជ័យជំនះនៅលើរាល់ការល្បួង

## ២. ខគម្ពីរសំខាន់ : ១ កូរិនថូស ១០ : ១៣

អ្នកមិនដែលធ្លាប់ជួបការល្បួងឱ្យប្រព្រឹត្តអំពើបាបនៅក្នុងវិធីផ្សេងៗគ្នាច្រើនជាងមនុស្សដទៃទៀតនោះធ្លាប់ទេ ។ ព្រះជាម្ចាស់ ទ្រង់ស្មោះត្រង់ ។ ទ្រង់មិនបណ្តោយអោយអ្នកជួបការល្បួងលើសពីសមត្ថភាពរបស់អ្នកនោះទេ ។ ប៉ុន្តែនៅពេលដែល អ្នកជួបការល្បួង ទ្រង់នឹងមានផ្លូវសំរាប់អ្នកមិនអោយធ្លាក់ទៅក្នុងការល្បួងនោះទេ ។

## ៣. សំភារៈសិក្សាយោងរបស់សិស្ស

នៅទំព័រ ទី ១៧ដល់ ទី ២៧ នៅក្នុងសៀវភៅណែនាំរបស់សិស្សដែលមានភ្ជាប់ជាមួយនឹងមេរៀននេះ ។ គំរោង ទី ២  និង ទី ៥ នៅក្នុងការណែនាំការសិក្សាអាចត្រូវបានប្រើជាមួយមេរៀននេះផងដែរ ។

## ៤. ការរៀបចំរបស់គ្រូសំរាប់មេរៀននៅក្នុងថ្នាក់នេះ

ប្រហែលជាកិច្ចការមួយដ៏សំខាន់បំផុតដែលអ្នកអាចធ្វើនៅក្នុងការរៀបចំសំរាប់មេរៀននេះគឺមើលការល្បួង ១ ឬក៏ ២ ដោយប្រើគំរោង ទី ៦ និង ទី៨ ជាគំរូរបស់អ្នក។ គន្លឹះដើម្បីធ្វើអោយមេរៀននេះជោគជ័យគឺត្រូវយល់ដឹងពីបទពិសោធន៍ពីរបៀបរៀបចំសំរាប់ការល្បួង ។

## ៥. ការចាប់ផ្តើមមេរៀន ដោយការកំដៅសាច់ដុំ

អ្នកប្រហែលជាចង់មានសិស្សខ្លះអោយធ្វើការចែកចាយពីបទពិសោធន៍ផ្ទាល់របស់ពួកគេនៃការព្យាយាមប្រើ  គំរូ ថ្មីនេះក្នុងការឆ្លើយតបចំពោះការល្បួងដែលយើងបានណែនាំអោយស្គាល់នៅមេរៀន ទី ១ ។ ប្រសិនបើអ្នកគិតថាសិស្សរបស់  អ្នកប្រហែលជាមិនចង់ចែកចាយចំលើយផ្ទាល់ខ្លួនរបស់ពួកគេ  នៅការចាប់ផ្តើមថ្នាក់រៀននោះទេ សូមមករៀបចំចែកចាយ ១ ឬក៏ ២ឧទាហរណ៍ពីជីវិតផ្ទាល់របស់អ្នក ។

## ៦. ជំនាញជាមូលដ្ឋានដែលចាំបាច់ដោះស្រាយជាមួយការល្បួង

ចំណាយពេលវេលា ២ឬក៏ ៣នាទីដើម្បីសង្កត់ទៅលើសារៈសំខាន់នៃការរៀបចំដើម្បីយកជ័យជំនះនៅលើការល្បួង។  មានជំនាញសំខាន់ៗ៣យ៉ាងដែលសិស្សរបស់អ្នកចាំបាច់បង្កើតឡើង  ប្រសិនបើពួកគេចង់មានភាពជោគជ័យនៅក្នុងការរៀបចំសំរាប់យកជ័យជំនះនៅលើការល្បួងអោយប្រព្រឹត្តអំពើបាប ។

ក.  មានលទ្ធភាពបង្ហាញការល្បួងនៅពេលដែលវាចាប់ផ្តើមភ្លាមៗ

ខ. មានលទ្ធភាពវាយតំលៃស្ថានភាព និង កំណត់អ្វីជាតំរូវការ ឬក៏ចំណង់ដែលសាតាំងវា កំពុងតែព្យាយាម បំពេញតំរូវការ និង ចំណង់ទាំងនោះ ។

គ. មានលទ្ធភាពរកអោយឃើញវិធីរបស់ព្រះជាម្ចាស់ដើម្បីបំពេញ*តំរូវការ* និង *ចំណង់*របស់ពួកគេ បន្ទាប់មកធ្វើតាមវិធីរបស់ព្រះជាម្ចាស់ ។

ឃ. ជំនាញសំខាន់ដទៃទៀតគឺមានលទ្ធភាពអាចបង្ហាញផលវិបាកនៃការដើរតាមវិធីរបស់ព្រះជាម្ចាស់ ឬក៏ វិធីរបស់អារក្សសាតាំងនៅក្នុងស្ថានភាពនៃការល្បួង ។ នេះគឺជាវិធីមួយដ៏ល្អដើម្បីជួយជំរុញអោយមនុស្ស ដើរតាមវិធីរបស់ព្រះជាម្ចាស់ ។

## ៧. ចូលកាន់តែជិតព្រះជាម្ចាស់ ( ៥-១០ នាទី)

ពិភាក្សាសារៈសំខាន់នៃការចូលខិតជិតទៅកាន់ព្រះជាម្ចាស់ជាវិធីមួយដ៏សំខាន់ដើម្បីរៀបចំសំរាប់ការល្បួង ។ សូមមើលទំព័រ ទី ១៧-១៨នៃសេចក្តីណែនាំរបស់សិស្សសំរាប់ពត៌មានបន្ថែមនៅលើចំនុចនេះ ។

## ៨. បំពេញតំរូវការរបស់អ្នកតាមផ្លូវរបស់ព្រះជាម្ចាស់ (១០-២០នាទី)

ពិភាក្សាពីបញ្ហាសំខាន់ដែលត្រូវបានលើកឡើងនៅក្នុងចំនុច ខ " បំពេញតំរូវការរបស់អ្នកតាមផ្លូវ របស់ព្រះជាម្ចាស់ ។ " សូមមើលទំព័រ ទី ១៩-២២នៅក្នុងសៀវភៅណែនាំរបស់សិស្ស។ សូមធ្វើអោយប្រាកដ ថា អោយមានឧទាហរណ៍ច្រើននិងករណីសិក្សាអោយបានច្រើនរៀបចំអោយរួចជាស្រេចដើម្បីប្រើនៅ ក្នុងការ ពិភាក្សាក្នុងថ្នាក់។ អ្នកប្រហែលជាចង់អោយសិស្សយោងទៅដល់ការល្បួងខ្លះៗដែលពួកគេបានធ្វើបញ្ជីនៅលើ គំរោង ទី ២ ឬក៏ គំរោង ទី ៥ ។ ចំណាយពេលវេលានៅក្នុងថ្នាក់ដើម្បីបង្ហាញពួកគេ ពីរបៀបប្រើព្រះគម្ពីរ ដើម្បីរកអោយឃើញអ្វីទៅជាវិធីរបស់ ព្រះជាម្ចាស់ក្នុងការបំពេញតំរូវការ និង ចំណង់ពិសេសណាមួយនោះ ។ ព្យាយាមអោយសិស្សធ្វើការវាយតំលៃដោយប្រុងប្រយត្ន័កិច្ចការដែលពួកគេបានធ្វើនៅលើគំរោង ទី ២ ជាពិសេសសំនួរ ទី ៤ និង ទី ៥នៅលើឧទាហរណ៏នីមួយៗ ។ ធ្វើការអង្កេតប្រសិនបើបានបង្ហាញយ៉ាងត្រឹម ត្រូវនៅ តំរូវការ និង ចំណង់ពិតប្រាកដនៅពីក្រោយការល្បួងនីមួយៗនោះ ។

តើពួកគេគ្រាន់តែបានបង្ហាញតំរូវការទប់ទល់ជាមួយការល្បួង ឬក៏ ពួកគេចូលទៅកាន់តែជ្រៅ និង ដោះស្រាយ ជាមួយតំរូវការ និង ចំណង់ពិតប្រាកដ ដែលមារសាតាំងចង់អោយពួកគេធ្វើ?

យោងទៅតាមទំព័រ ទី ៧-៨ នៅក្នុងសៀវភៅការណែនាំរបស់សិស្សសំរាប់បញ្ជីដែលពិស្តារនៃតំរូវការនៅក្នុង ជីវិតរបស់យើង ។

## ៩. បញ្ជាក់ភាពខុសគ្នារវាងតំរូវការ និង ចំណង់ (៣-៥ នាទី)

បញ្ហាសំខាន់ដែលបន្តមកទៀតនោះ យើងនឹងត្រូវបង្រៀនគឺចំនុច គ " សូមអោយព្រះជាម្ចាស់ កំណត់ ចំណង់សមរម្យ ។ " បញ្ហានេះមាននៅលើទំព័រទី ២២-២៥ នៅក្នុងការណែនាំរបស់សិស្ស ។ សូមធ្វើអោយ ប្រាកដថាដំបូង ពួកគេយល់ដឹងភាពខុសគ្នារវាងចំណង់ និង តំរូវការ ។ ការបង្ហាញជាច្រើននៅចំនុចនេះ នឹងមាន

ប្រយោជន៏ច្រើន ។

អ្នកប្រហែលជាចង់យោងទៅចំនុច ១២-១៤ នៅក្នុងផែនការរៀបចំមេរៀនសំរាប់គ្រូ សំរាប់មេរៀនទី១ ( ទំព័រទី៧ និង ៨) សំរាប់ព័ត៌មានបន្ថែមស្ដីពីភាពខុសគ្នារវាងតំរូវការ និង ចំណង់ ។ ការបង្រៀនលើបញ្ហានេះម្ដងទៀតជាការសំខាន់ណាស់សំរាប់សិស្ស ។ អ្នកត្រូវធានាថា សិស្សរបស់អ្នកយល់ក្នុងការអនុវត្តន៏សេចក្ដីបង្រៀននេះនៅក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេបាន ។

**១០. តើចំណង់អ្វីដែលព្រះជាម្ចាស់អនុញ្ញាតអោយមាន? (៥-១៥ នាទី)**

អោយសិស្សបង្ហាញដល់អ្នកតើមានចំណង់អ្វីខ្លះរបស់ព្រះជាម្ចាស់ដែលយើងគួរតែមាន ។ អ្នកប្រហែលជាចង់ផ្ដល់អោយពួកគេនៅអត្ថបទគម្ពីរខ្លះ ដើម្បីរកមើលប្រសិនបើពួកគេមិនអាចមានគំនិតជាច្រើននោះ។ សូមមើលទំព័រ ទី ២២ និង ២៣ នៅក្នុងការណែនាំរបស់សិស្សសំរាប់អត្ថបទគម្ពីរខ្លះដែលអ្នកអាចប្រើនៅទីនេះបាន ។

**១១. ចំណង់ដែលជាអំពើបាប (៥-១៥ នាទី)**

អោយសិស្សធ្វើបញ្ជីចំណង់បាបដែលពួកគេចាំបាច់ត្រូវតែលះបង់ចោល ។ សង្កត់ទៅលើសារៈសំខាន់នៃការធ្វើកិច្ចការនេះ ច្រើនជាងលះបង់នៅចំណង់ចាស់ទាំងនេះចោល ។ ចំណង់ទាំងនេះត្រូវតែជំនួសជាមួយនឹងចំណង់ដែលមកពីព្រះជាម្ចាស់ ប្រសិនបើពួកគេចង់ឃើញស្ថេរភាពពិតប្រាកដនៅក្នុងជីវិត ជាគ្រីស្ទបរិស័ទរបស់ពួកគេ។ សូមមើលទំព័រ ទី ២៣ -២៥ នៅក្នុង ការណែនាំរបស់សិស្សសំរាប់ព័ត៌មាន បន្ថែមនៅក្នុងវគ្គសិក្សានេះ ។ អ្នកប្រហែលជាចង់អោយសិស្សខ្លះពន្យល់នៅក្នុងថ្នាក់ ពីរបៀបដែលពួកគេអាចលះបង់ចំណង់បាបចាស់ទាំងនោះចោល ។

**១២. ការល្បួងខ្លះអាចការពារបាន (១០-២០ នាទី )**

ក្នុងការបង្រៀនប្រធានបទ " ការល្បួងខ្លះអាចការពារបាន " សូមធ្វើអោយប្រាកដថា អ្នកមានឧទាហរណ៏ច្បាស់លាស់ខ្លះៗដើម្បីពន្យល់បង្ហាញកិច្ចការនេះ ។ សូមមើលចំនុច ឃ នៅលើ ទំព័រ ទី ២៥-២៧នៅក្នុងសៀវភៅណែនាំរបស់សិស្សសំរាប់ព័ត៌មានបន្ថែមនៅលើបញ្ហានេះ ។ សូមអោយសិស្សខ្លះផ្ដល់ឧទាហរណ៏ពីរបៀបដែលពួកគេធ្លាប់បានការពារការល្បួងចំនួនបាន ។

**១៣. គំរូនៃគំរោងទី ៨ (១០-២០ នាទី )**

មុននឹងបញ្ចប់មេរៀននៅក្នុងថ្នាក់ អ្នកប្រហែលជាចង់យកការល្បួងពិសេសមួយ និង ធ្វើនៅក្នុងគំរោង ទី៨ នៅក្នុងថ្នាក់។ កិច្ចការនេះនឹងជួយពួកគេអោយយល់ដឹងពីរបៀបបំពេញកិច្ចការនៅលើគំរោងនេះដែល ពួកគេនឹងត្រូវធ្វើបន្ទាប់ពីបញ្ចប់ថ្នាក់រៀននេះទៅ ។

**១៤. ការអនុវត្តន៏ផ្ទាល់ខ្លួន**

ការអនុវត្តន៏ផ្ទាល់ខ្លួនសំរាប់មេរៀននេះនឹងផ្ដោតទៅលើសិស្សម្នាក់ៗយកនូវឧទាហរណ៏ពិសេសមួយ និង

បំពេញគំរោង ទី ៨ ។ ពួកគេនឹងមិនធ្វើកិច្ចការនេះនៅក្នុងថ្នាក់នោះទេ ។

លើកទឹកចិត្តសិស្សអោយព្យាយាមប្រើអ្វីដែល ពួកគេបានរៀន នៅពេលដែលពួកគេប្រឈមមុខនឹងការល្បួងអោយប្រព្រឹត្តអំពើបាប ។

**១៥. កិច្ចការត្រូវធ្វើ**

ក. ដាក់ពិន្ទុ គំរោង ទី ៥ និង ទី ២ ប្រសិនបើអ្នកមិនទាន់បានដាក់ពិន្ទុនោះទេ ។

ខ. ដាក់ពិន្ទុគំរោង ទី ៧

គ. ពេលបញ្ចប់មេរៀននៅក្នុងថ្នាក់ ធ្វើសំនួរខ្លីនៅលើ យ៉ាកុប ៤ : ៧-៨ ។

**១៦. ការវាយតំលៃមេរៀន**

សូមបង្ហាញគំនិតរបស់អ្នកសំរាប់ធ្វើអោយមេរៀននេះកាន់តែប្រសើរឡើង ។ តើផ្នែកណាដែលល្អបំផុត? តើចំនុចណាដែលពិបាកបំផុតសំរាប់សិស្សក្នុងការស្វែងយល់ដឹង? តើចំនុចមួយណាមើលទៅវាមានប្រយោជន៏ដល់សិស្សរបស់អ្នក?

# មេរៀន ទី ៨

# ការឆ្លើយតបនៅនឹងការបរាជ័យ

## ១. សេចក្ដីពិតសំខាន់ៗនៅក្នុងព្រះគម្ពីរ

ខ្ញុំចាំបាច់ត្រូវតែរៀនឆ្លើយតបចំពោះការបរាជ័យរបស់ខ្ញុំនៅក្នុងផ្លូវមួយ ដែលនឹងជួយខ្ញុំអោយខិតទៅកាន់តែ ជិតព្រះជាម្ចាស់ ។

## ២. ខគម្ពីរសំខាន់ : ហេប្រឺ ៤:១៥-១៦

ដ្បិតយើងមានមហាបូជាចារ្យដែលអាចរួមសុខទុក្ខជាមួយយើងជាមនុស្សទន់ខ្សោយគឺ ព្រះអង្គក៏ត្រូវរងការល្បួងលគ្រប់ជំពូកដូចយើងដែរ តែទ្រង់មិនបានប្រព្រឹត្តអំពើបាបសោះឡើយ ។ ហេតុនេះ យើងត្រូវតែចូលទៅកាន់បល្ល័ង្ករបស់ព្រះជាម្ចាស់ប្រកបដោយព្រះហឫទ័យប្រណីសន្ដោសទាំងទុកចិត្ត ដើម្បីអោយព្រះអង្គមេត្តាករុណា និង ប្រណីសន្ដោសយើង ព្រមទាំងជួយយើងនៅពេលណាយើងត្រូវការ ។

## ៣. សំភារៈសិក្សាយោងសំរាប់សិស្ស

សូមមើលទំព័រ ទី ២៨-៣៨ នៅក្នុងសៀវភៅណែនាំរបស់សិស្សស៊ីគ្នាជាមួយនឹងមេរៀននេះ ។ គំរោង ទី ៤ និង ទី ៧ នៅក្នុងសៀវភៅណែនាំការសិក្សាអាចត្រូវបានប្រើផងដែរនៅក្នុងមេរៀននេះ ។

## ៤. ទស្សនៈពីរ នៃការបរាជ័យ

នៅពេលចាប់ផ្ដើមមេរៀនថ្ងៃនេះ សូមចង្អុលបង្ហាញថា ការនិយាយអំពីការបរាជ័យមិនគួរត្រូវបានគេមើលឃើញថា ជាការយល់ព្រមជាមួយវានោះទេ ។ គ្រីស្ទបរិស័ទដែលកំពុងតែស្វែងរកនូវការធ្វើតាមផ្លូវរបស់ព្រះជាម្ចាស់ នឹងមិនធ្វើអំពើបាបតាមធម្មតាទេ ហើយ និយាយទៅកាន់ខ្លួនគាត់ថា " វាមិនជាបញ្ហាអីទេ ។ ព្រះជាម្ចាស់នឹងអត់ទោសអោយខ្ញុំ ប្រសិនបើខ្ញុំសូមអោយទ្រង់អត់ទោសអោយខ្ញុំ ។ " ព្រះជាម្ចាស់មិនចង់អោយយើងធ្វើតាមការល្បួងនោះទេ ។ យើងត្រូវតែមានអាកប្បកិរិយាដូចព្រះជាម្ចាស់ ។

ប៉ុន្តែម៉្យាងវិញទៀត យើងភាគច្រើនបានធ្វើតាមការល្បួងពីមួយថ្ងៃទៅមួយថ្ងៃ ។ គោលបំណងនៅក្នុងមេរៀននេះគឺដើម្បីមើលអោយឃើញនូវហេតុផលថាតើហេតុអ្វីបានជាយើងបរាជ័យ និង មើលនូវផលវិបាកនៃការបរាជ័យរបស់យើង ។ យើងក៏នឹងមើលផងដែរ ថាតើគ្រីស្ទបរិស័ទគួរតែឆ្លើយតបយ៉ាងដូចម្ដេចចំពោះការបរាជ័យនេះ ។

ការបរាជ័យក្នុងការទប់ទល់នឹងការល្បួងមិនមែនមានន័យថាមនុស្សបាត់បង់ការសង្គ្រោះរបស់គាត់ នៅត្រង់ចំនុចនោះនោះទ ។ គ្មាននរណាម្នាក់ល្អឥតខ្ចោះនោះទេ ប៉ុន្តែយើងទាំងអស់គ្នាត្រូវតែស្មោះត្រង់ក្នុង ការព្យាយាម អោយអស់ពីសមត្ថភាពរបស់យើងដើម្បីទប់ទល់នឹងការល្បួង ។ នៅពេលដែលយើងបរាជ័យ យើងត្រូវតែមានភាពស្មោះត្រង់ សូមសារភាពការនោះធ្វើដូច្នេះ យើងនឹងរីកចំរើនខ្លាំងឡើងថែមទៀត

នៅពេលដែល យើងជួបការល្បួងដដែលនោះម្តងទៀតនៅពេលក្រោយ យើងនឹងមានវិធីល្អប្រសើរ ដើម្បីទល់ទល់នឹងការនោះបាន ។

**៥. តើអ្វីនឹងកើតឡើង នៅពេលដែលអ្នកធ្វើតាមការល្បួង?**

ចាប់ផ្តើមការពិភាក្សានៅក្នុងថ្នាក់ថ្ងៃនេះដោយបង្ហាញបញ្ហា " តើអ្វីនឹងកើតឡើង នៅពេលដែលយើងធ្វើតាមការល្បួង? " សូមមើល ទំព័រ ទី ២៨-៣៣ នៅក្នុងសៀវភៅណែនាំរបស់សិស្សសំរាប់ព័តិមានបន្ថែមនៅលើចំនុចនេះ ។ សូមផ្តល់ពេលវេលាអោយសិស្សចែកចាយនូវឧទាហរណ៍ខ្លះៗនៃផលវិបាកដែលពួកគេមានពិសោធន៏ បន្ទាប់ពីធ្វើតាមការល្បួង ។

សូមចំណាយពេលវេលាផងដែរដោយមើលទៅលើផលវិបាកដែលបានកើតឡើងនៅក្នុងរឿងរបស់ព្រះគម្ពីរនៅលើគំរោង ទី ៤ និង ទី ៧ ។ សូមជ្រើសរើសរឿងមួយដែលអ្នកគិតថាមានប្រយោជន៏បំផុត ចំពោះសិស្សរបស់អ្នក ។

**៦. ហេតុអ្វីបានជាមនុស្សធ្វើតាមការល្បួង? (៥-១០ នាទី )**

សូមប្រើឧទាហរណ៍ដូចគ្នាខាងព្រះគម្ពីរពីគំរោង ទី ៤ និង ទី ៧ ក្នុងការពិភាក្សាថាតើហេតុអ្វីបានជាមនុស្សធ្វើតាមការល្បួង ។ សូមមើលទំព័រ ទី ៣៣-៣៦ នៅក្នុងសៀវភៅណែនាំរបស់សិស្សសំរាប់ព័តិមានបន្ថែមនៅលើចំនុចនេះ ។ ដោយមានឧទាហរណ៏ច្រើនខាងព្រះគម្ពីរ អ្នកអាចស្មានថាតើអ្វីទៅជាហេតុផលដែលបណ្តាលអោយគេធ្វើតាមការល្បួង ព្រោះព្រះគម្ពីរមិនបានបង្ហាញហេតុផលថាតើហេតុអ្វីបានជាពួកគេធ្វើតាមការល្បួងនោះទេ ។

**៧. ការវាយតំលៃរបស់សិស្សនៃការបរាជ័យក្នុងអតីតកាលរបស់ពួកគេ**

សូមអោយសិស្សធ្វើការវាយតំលៃការល្បួងមួយ ឬក៏ ពីរនៅក្នុងជីវិតផ្ទាល់របស់ពួកគេដែលពួកគេបានធ្វើតាមការល្បួងនោះ ។ តើពួកគេអាចរកឃើញហេតុផលថាតើហេតុអ្វីបានជាពួកគេធ្វើតាមការល្បួងឬទេ? ប្រហែលជាកិច្ចការជាច្រើនជួបផ្សំទៅនឹងការបរាជ័យរបស់ពួកគេផងដែរ ។ ពួកគេអាចយោងទៅតាមការល្បួងខ្លះៗដែលពួកគេបានប្រើនៅលើគំរោងរបស់ពួកគេសំរាប់មុខវិជ្ជានេះ ។

សូមចង្អុលបង្ហាញពីសារៈសំខាន់ក្នុងការរកអោយឃើញនូវហេតុផលថាតើហេតុអ្វីបានជាគេធ្វើតាមការល្បួង ។ កិច្ចការនេះអាចជួយពួកគេអោយយល់ដឹងកន្លែងខ្លះ ដើម្បីចាប់ផ្តើមក្នុងការរៀបចំសំរាប់ការល្បួងក្នុងពេលអនាគត ។

**៨. តើអ្នកគួរតែធ្វើអ្វីប្រសិនបើអ្នកធ្វើតាមការល្បួង? (១០-១៥ នាទី)**

សូមផ្តល់នូវការយកចិត្តទុកដាក់យ៉ាងប្រុងប្រយត្ន័ចំពោះការពិភាក្សា តើមនុស្សម្នាក់គួរតែធ្វើអ្វី បន្ទាប់ពីគាត់បានធ្វើតាមការល្បួង ។ សូមមើលទំព័រ ទី ៣៧-៣៨ នៅក្នុងសៀវភៅណែនាំរបស់សិស្សសំរាប់ ព័តិមានបន្ថែមនៅលើប្រធានបទនេះ ។ បន្ទាប់ពីពិភាក្សាបញ្ហាផ្សេងៗនៅក្នុងផ្នែកនេះ សូមលើកទឹកចិត្ត ពួកគេអោយ

ប្រើគំនិតទាំងនេះ នៅក្នុងពេលវេលាស្ងាត់ស្ងៀមរបស់ពួកគេនៅពេលអធិស្ឋាន អំពីការល្បួងផ្សេងៗ ដែលពួកគេបានធ្វើនោះ ។

**៩. របៀបដែលព្រះជាម្ចាស់បានឆ្លើយតបទៅនឹងមនុស្សមួយចំនួន នៅក្នុងព្រះគម្ពីរ ដែលបានទទួលការបរាជ័យ** ( ៥-១០នាទី )

នៅក្នុងការពិភាក្សានូវអ្វីដែលមនុស្សម្នាក់ គួរធ្វើ ក្រោយពីគាត់បានធ្វើតាមការល្បួង ប្រហែលជាអ្នកអាចសិក្សាបន្ថែមទៀតស្តីពីអត្តចរិកមួយចំនួននៅក្នុងព្រះគម្ពីរ ដែលបានឆ្លើយតបទៅនឹងការបរាជ័យរបស់ពួកគេ ។ ព្រះបាទដាវីឌ និង លោកពេត្រុសបានសារភាពនូវអំពើបាបរបស់ពួកគេ តែឯលោកយូដាសវិញមិនបានសារភាពទេ ។ ប្រហែលជាអ្នកគួរតែពិភាក្សាស្តីពីការឆ្លើយតបរបស់ព្រះជាម្ចាស់ ចំពោះមនុស្សដែលបានសារភាពនូវអំពើបាបរបស់ពួកគេ ។ ព្រះបាទដាវីឌនៅតែបន្តធ្វើជាមហាក្សត្រ ហើយ ពេត្រុសវិញក៏បានបន្តក្លាយខ្លួនជាអ្នកដឹកនាំក្រុមជំនុំដ៏សំខាន់ផងដែរ ។

**១០. សូមធ្វើការសន្យាថា អ្នកនឹងមិនដែលធ្លាក់ក្នុងការប្រព្រឹត្តអំពើបាបម្តងទៀតឡើយ ( ៥-១០នាទី)**

សូមពន្យល់ដល់សិស្សរបស់អ្នកថា ពួកគេមិនគួរស្បថចំពោះព្រះជាម្ចាស់បន្ទាប់ពីពួកគេបានធ្វើតាមការល្បួងនោះទេ ។ គ្រីស្តបរិស័ទខ្លះប្រហែលជាគិតថា វាគឺជាការឆ្លើយតបខាងព្រលឹងវិញ្ញាណដ៏ល្អមួយក្នុងការស្បថ " ព្រះជាម្ចាស់ ទូលបង្គំទើបតែធ្វើតាមការល្បួង ទូលបង្គំសន្យាថា ទូលបង្គំនឹងមិនធ្វើតាមការល្បួងម្តងទៀតនោះទេ ។ " ការស្បថប្រភេទនេះ ជួយដោះស្រាយបញ្ហាពិតប្រាកដតិចតួចណាស់ ។ អារក្សសាតាំងអាចប្រើកិច្ចការនេះជាផ្លូវមួយក្នុងការផ្តន្ទាទោសកាន់តែខ្លាំងឡើងថែមទៀតនៅលើមនុស្ស បន្ទាប់ពីពួកគេបានធ្លាក់ម្តងទៀតនៅពេលអនាគត ។

ប្រសិនបើពួកគេចង់ស្បថចំពោះព្រះជាម្ចាស់ វាប្រហែលជាសមរម្យជាងនិយាយថា " ព្រះជាម្ចាស់ ទូលបង្គំចង់ស្បថថា ទូលបង្គំនឹងចូលទៅជិតព្រះអង្គរាល់ថ្ងៃ ។ ទូលបង្គំក៏សន្យាផងដែរក្នុងការចំណាយពេលវេលារយៈពេលប៉ុណ្ណេះ _______ដើម្បីសិក្សានូវអ្វីដែលទ្រង់មានព្រះបន្ទូលអំពីការល្បួងនេះ និង ពីរបៀបដែលទូលបង្គំអាចឆ្លើយតបនៅក្នុងផ្លូវដែលនឹងសព្វព្រះហឫទ័យរបស់ទ្រង់ ។ "

ការសន្យាប្រភេទនេះវាងាយស្រួលជាងដើម្បីរក្សាការសន្យា និង នៅក្នុងរយៈពេលដ៏យូរវាកាន់តែធ្វើអោយអ្នកបង្កើតនូវទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងព្រះជាម្ចាស់ទៀតផង ។

**១១. ការអនុវត្តន៍ផ្ទាល់ខ្លួន ( ៥នាទី)**

សូមផ្តោតទៅលើការអនុវត្តន៍ផ្ទាល់ខ្លួនដោយមានភាពស្មោះត្រង់ជាមួយនឹងព្រះជាម្ចាស់អំពីការបរាជ័យរបស់ពួកគេ ។ ពួកគេត្រូវតែសារភាពអំពើបាបរបស់ពួកគេអោយបានលឿន ។ ពួកគេត្រូវតែរៀនពីកំហុសរបស់ពួកគេផងដែរ ។ កំហុសទាំងនេះអាចជួយអោយពួកគេមើលឃើញកន្លែងដែលពួកគេត្រូវធ្វើអោយប្រសើរឡើងក្នុងការរៀបចំសំរាប់ការល្បួងពេលអនាគត ។

## ១២. កិច្ចការត្រូវធ្វើ

ក. ដាក់ពិន្ទុគំរោង ទី ៨ ។ អ្នកអាចតំរូវអោយសិស្សរបស់អ្នកឆ្លើយសំនួរ ទី ៧ នៅក្នុងគំរោងនោះ មុននឹងប្រគល់វាជូនអ្នក ។ ប្រសិនបើអ្នកតំរូវអោយធ្វើកិច្ចការនេះ សិស្សខ្លះប្រហែលជាត្រូវការពេលវេលាច្រើនថ្ងៃទៀតបញ្ចប់គំរោងនោះ វាអាស្រ័យទៅលើថាតើពេលណាពួកគេប្រឈមមុខនឹងការល្បួង ដែលពួកគេបានប្រើនៅលើគំរោងរបស់ពួកគេ ។

ខ. នៅបញ្ចប់ថ្នាក់រៀន សូមផ្តល់សំនួរខ្លីៗនៅលើជំហានទាំង ៦ ក្នុងការយកជ័យជំនះលើការល្បួង ។

## ១៣. ការវាយតំលៃមេរៀន

សូមរៀបរាប់ពីគំនិតរបស់អ្នកសំរាប់កែលំអមេរៀននេះនៅលើកក្រោយ ។ តើផ្នែកណាខ្លះ ដែលសំខាន់ខ្លាំង? ហើយតើផ្នែកណាខ្លះ ដែលពិបាកបំផុតសំរាប់សិស្ស? តើអ្វីខ្លះដែលអាចមានប្រយោជន៏ខ្លាំងចំពោះសិស្សរបស់អ្នក?

# មេរៀន ទី ៥ :

## ការប្រឡង

**១. ណែនាំអោយស្គាល់នូវមុខវិជ្ជាដែលអ្នកនឹងបង្រៀនពេលក្រោយ**

**ក.** ចែកសៀវភៅណែនាំរបស់សិស្សដល់ពួកគេ និង សៀវភៅការណែនាំការសិក្សា ហើយបែងចែកគំរោងដែលត្រូវបំពេញមុនរៀនមេរៀនបន្ទាប់ទៀតដែលអ្នកនឹងត្រូវបង្រៀន ។

**ខ.** អោយសិស្សមើលនៅទំព័រចុងក្រោយនៃសៀវភៅការណែនាំការសិក្សារបស់ពួគេ ។ ពួកគេនឹងឃើញបញ្ជីកិច្ចការត្រូវធ្វើនៅក្នុងថ្នាក់ ។ ផ្តល់នៅកាលបរិច្ឆេទសំរាប់សំនួរខ្លីៗ, គំរោង និង ការប្រលងនីមួយៗ ។

**២. ផ្តល់ការប្រលងនៅលើវគ្គសិក្សានេះ**

**៣. សូមប្រគល់សំនួរប្រលងខ្លីៗ និង គំរោងដែលអ្នកបានដាក់ពិន្ទុរួចហើយទាំងអស់ដល់សិស្ស ប្រសិនបើអ្នកមិនទាន់បានប្រគល់ជូននៅឡើយនោះ ។**